# គ.ជ.បនឹងរៀបចំបញ្ជីឈ្មោះដើម្បីកំណត់អ្នកទៅ និងមិនបានទៅបោះឆ្នោត



*លោក ហង្ស ពុទ្ធា សមាជិក គ.ជ.ប និងជាអ្នកនាំពាក្យ ផ្តល់បទសម្ភាសន៍ជុំវិញការចាប់ផ្តើមបើកដំណើរការនៃការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅទីស្តីការ គជប។ រូបថតនៅថ្ងៃទី២០ ខែឧសភា ឆ្នា២០២២។ (រូបភាព៖ គេហទំព័រ គជប)*

មន្ត្រីជាន់ខ្ពស់ស្ថាប័នជាតិរៀបចំការបោះឆ្នោត លើកឡើងថានៅចំពោះមុខនេះ ស្ថាប័នគ.ជ.ប កំពុងតែពិនិត្យអំពីលទ្ធភាពក្នុងការរៀបចំបញ្ជី និងនីតិវិធីដើម្បីទុកស្រង់ឈ្មោះក្រោយថ្ងៃទី ២៣ ខែកក្កដា

ចំពោះអ្នកដែលបានទៅ និងមិនបានទៅបោះឆ្នោតដែលបម្រើឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧។

លោក ហង្ស ពុទ្ធា មន្ត្រីនាំពាក្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ប្រាប់ឱ្យដឹងថា ដើម្បីសម្រួលដល់ការលំបាកក្នុងការកត់ចំណាំ និងតួលេខពិតប្រាកដ អ្នកដែលបានទៅបោះឆ្នោត ឬមិនបានបោះឆ្នោត ស្ថាប័ន គ.ជ.ប កំពុងតែរៀបចំធ្វើជាបញ្ជីឈ្មោះមួយសម្រាប់អាណត្តិនេះ។លោកបន្តថានីតិវិធីថ្មីនេះវានឹងជួយឱ្យ គ.ជ.ប អាចរកឃើញពីអត្តសញ្ញាណពិតប្រាកដអ្នកដែលចូលរួមបោះឆ្នោត ឬអ្នកដែលបោះបង់សិទ្ធិក្នុងការបោះឆ្នោត។

លោកបន្តថា៖«*ប្រសិនបើអនុម័តច្បាប់ជាផ្លូវការហើយ គ.ជ.ប គ្រាន់តែគិតគូរអំពីនីតិវិធីនៃការគ្រប់គ្រងឱ្យដឹងតួលេខនិងឈ្មោះពិតប្រាកដអ្នកដែលបានអញ្ជើញមកបោះឆ្នោតនិងមិនបានមកបោះឆ្នោត*»។

ទោះជាយ៉ាងណាក៏ដោយ លោក ហង្ស ពុទ្ធា ឱ្យដឹងថា សមាជិកទាំង៩រូបដែលដឹកនាំដោយលោក ប្រាជ្ញ ច័ន្ទ ប្រធាន គ.ជ.ប ក៏នឹងពិភាក្សាលម្អិតបន្ថែមទៀត ជាមួយតួអង្គពាក់ព័ន្ធអំពីលើខ្លឹមសារ នៃវិសោធនកម្មច្បាប់ ក្រោយឆ្លងកាត់ដៃរដ្ឋសភារួច។ក្នុងន័យនេះលោកថា ការដាក់ឱ្យមានការពិគ្រោះយោបល់គឺសំដៅដល់ការកំណត់ហេតុផលសមរម្យសម្រាប់ពលរដ្ឋដែលមិនបានទៅចូលរួមបោះឆ្នោត។

បន្ថែមពីលើនេះ ប្រសិនបើក្នុងករណីពលរដ្ឋជាប់បេសកម្មក្រៅប្រទេស មានជំងឺធ្ងន់ធ្ងរ និងជាប់ពន្ធនាគារជាដើម ដែលមិនអាចទៅបោះឆ្នោតបាន វាសុទ្ធតែជាហេតុផលសមស្របដែលអាចទទួលយកបាន។

លោកបន្តថា៖ *«នៅពេលដែលច្បាប់ចេញហើយ គ.ជ.ប ចាប់ផ្តើមជជែកគ្នាហើយថាយ៉ាងម៉េចទៅដែរថាសមរម្យ»*។

ចំណែកអ្នកនាំពាក្យរដ្ឋសភាលោក ឡេង ប៉េងឡុង ឱ្យដឹងនៅថ្ងៃទី២២ នេះថាសេចក្តីព្រាងនៃវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតនេះ រដ្ឋសភានឹងអនុម័តជាផ្លូវការ នៅថ្ងៃទី ២៣ ខែ មិថុនា។

នៅក្នុងជំនួបជាមួយកម្មកររោងចក្រ កាលពីថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០២៣ លោកនាយរដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាឱ្យលោក ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោក កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រៀបចំព្រាងវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតដោយប្រញាប់ប្រញាល់។

បើតាមលោក ហ៊ុន សែន គោលបំណងនៃការកែច្បាប់នេះ គឺជាការបិទផ្លូវជីវិតនយោបាយ របស់ក្រុមអ្នកនយោបាយបក្សប្រឆាំង និងអ្នកដែលមានបំណងឈរឈ្មោះឱ្យគេបោះឆ្នោត នៅអាណត្តិបន្តបន្ទាប់ទៀតដែរ។បីថ្ងៃក្រោយ វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតនេះ បានធ្លាក់ចូលដល់ដៃស្ថាប័នរដ្ឋសភា នៅថ្ងៃទី១៥ ខែមិថុនា។

ដោយឡែក អ្នកនាំពាក្យគណបក្សភ្លើងទៀន លោក គីម សួរភីរិទ្ធ ថ្លែងថា លោកនឹងរង់ចាំការសម្រេចពី គ.ជ.ប ជុំវិញការកំណត់ហេតុផលសមរម្យនេះ ត្រូវដំណើរការបែបណា។លោកបន្តថាការធ្វើវិសោធនកម្មនេះមានបំណងដកហូតសិទ្ធិបន្ថែមលើប្រជាពលរដ្ឋ ខណៈការកែច្បាប់យ៉ាងឆាប់រហ័សបែបនេះគឺមិនបានសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយនោះទេ។

ជាងនេះទៀត លោក គីម សួរភីរិទ្ធ មានមន្ទិលថា តើការកែច្បាប់យ៉ាងតក់ក្រហល់នេះ លោក ហ៊ុន សែន ទំនងចង់ដាក់គំនាបលើក្រុមមនុស្សណាមួយឱ្យប្រាកដ។

លោកបន្តថា៖*«ខ្ញុំមិនដឹងថាពាក្យសមរម្យកំណត់យ៉ាងម៉េច ខាងគ.ជ.ប ឱ្យនិយមន័យច្បាស់សិនមកចាំគិតទៀត»*។

តាមរយៈសារសំឡេងដែលត្រូវបានផ្សព្វផ្សាយកាលពីយប់ថ្ងៃចន្ទសប្តាហ៍មុន លោក ហ៊ុន សែន អះអាងថា ការកែច្បាប់បោះឆ្នោតនេះ វាគឺជាការដាក់បន្ទុកលើមេដឹកនាំនយោបាយឱ្យមានទំនួលខុសត្រូវក្នុងនាមជាពលរដ្ឋគំរូ។

លោកបន្តថា៖*«បើខ្លួនមិនអាចបំពេញកាតព្វកិច្ចក្នុងឋានៈជាពលរដ្ឋល្អសម្រាប់ការបោះឆ្នោតតើមានហេតុផលអ្វីដែលនឹងត្រូវមានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត»*។

ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតលើកនេះ ក្រសួងយុត្តិធម៌ បានយកច្បាប់ចំនួន៤ច្បាប់ មកកែប្រែដូចដែលលោកនាយរដ្ឋមន្ត្រី ហ៊ុន សែន តម្រូវឱ្យព្រាងដោយប្រញាប់ រួមមានច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ,ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ-សង្កាត់, ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

នៅក្នុងបញ្ញត្តិបន្ថែមសម្រាប់វិសោធនកម្មនេះ គឺបានដាក់បន្ថែមនូវទណ្ឌកម្ម និងលក្ខខណ្ឌមួយចំនួនសម្រាប់ពលរដ្ឋដែលចង់ឈរឈ្មោះបោះឆ្នោត។សម្រាប់ច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រតម្រូវឱ្យពលរដ្ឋដែលចង់ឈរឈ្មោះឱ្យគេបោះឆ្នោតលុះត្រាខ្លួនបានចូលរួមបោះឆ្នោតសកល២លើកជាប់គ្នា ទើបអាចមានសិទ្ធិទៅឈរឈ្មោះ ឱ្យគេបោះឆ្នោតឱ្យបាន។

ដោយឡែក ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា-ឃុំ សង្កាត់វិញ គឺតម្រូវឱ្យពលរដ្ឋត្រូវចូលរួមបោះឆ្នោតសកលលើកចុងក្រោយ។ច្បាប់នេះក៏បានកំណត់ថា ជនណា ឬគណបក្សនយោបាយដែលរារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត ឬធ្វើឱ្យខូចសន្លឹកឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ឬគណបក្សនយោបាយ និងដកសិទ្ធិឈរឈ្មោះ

បោះឆ្នោតរយៈពេល៥ឆ្នាំ ឬបើគណបក្សនយោបាយអាចត្រូវដកសិទ្ធិមិនចូលរួមការបោះឆ្នោត៥ឆ្នាំយ៉ាងតិច។

ក្រៅពីនេះ ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តម្រូវឱ្យពលរដ្ឋបានទៅចូលរួមបោះឆ្នោតសកលលើកចុងក្រោយ។

ទាក់ទិនរឿងនេះលោកស្រី ចក់ សុភាព នាយិកាប្រតិបត្តិ នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា យល់ឃើញថា វិសោធនកម្មច្បាប់នេះហាក់ព្យាយាមដាក់គំនាបចំពោះប្រជាពលរដ្ឋដែលមានបំណងឈរឈ្មោះប្រកួតប្រជែងក្នុងការបោះឆ្នោតជាមួយគណបក្សកាន់អំណាច។

លោកស្រីបន្តថា៖«*ពេលនេះវិសោធនកម្មបានចងបន្ទុកតម្រូវអ្នកឈរឈ្មោះបោះឆ្នោតត្រូវទៅបោះឆ្នោតជាសកលចំនួនពីរលើកចុងក្រោយជាប់គ្នា លើកលែងករណីមានមូលហេតុសមស្រប។តើមូលហេតុសមស្របនឹងត្រូវបានវាយតម្លៃបែបណា?*»។

នៅដើមឆ្នាំ២០១៧ រដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា [បានធ្វើវិសោធនកម្មច្បាប់ស្ដីពីគណបក្សនយោបាយ] ហើយបើកផ្លូវឱ្យក្រសួងមហាផ្ទៃ អាចប្ដឹងទៅតុលាការកំពូល ក្នុងការរំលាយគណបក្សនយោបាយណាដែលរកឃើញថា បានប្រព្រឹត្តខុសទៅនឹងរដ្ឋធម្មនុញ្ញ ច្បាប់ស្ដីពីគណបក្សនយោបាយ និងច្បាប់ដទៃទៀត។

ជាមួយគ្នានេះ វិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយក្នុងឆ្នាំដដែល បានអនុញ្ញាតឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បែងចែកអាសនៈទាំងអស់របស់គណបក្សដែលត្រូវបានរំលាយទាំងក្នុងរដ្ឋសភា និងអាសនៈឃុំ-សង្កាត់ ទៅបែងចែកឱ្យបក្សផ្សេងទៀតដែលបានចូលរួមការបោះឆ្នោត៕